មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ចូវ ឌីនញី** (CHAU DINH NHI) ជនជាតិវៀតណាម សញ្ជាតិបារាំង កើតនៅខេត្ត ចូឡុង ប្រទេសវៀតណាម ១០៦៦

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ហាន់ដា ហារុហ៊ីសា** (HANDA HARUHISA) សញ្ជាតិជប៉ុន កើតនៅយ៉ូហ្គូ ព្រីហ្វិចហ្សើ ប្រទេសជប៉ុន ១០៦៧

១១-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៨ ស្តីពីការតែងតាំងឯកឧត្តម **នីវ សិន** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ១០៦៨

II~ព្រឹទ្ធសភា~រដ្ឋសភា~ក្រុមប្រឹក្សាធម្មនុញ្ញ

១៦-០២-២០០៦ -សេចក្តីសម្រេចរួមលេខ ០២ ព.រ.ក ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន របស់មន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ ១០៦៩

III~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១៦-០២-២០០៦ -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកិច្ចការនារី ១០៧១

១៧-០២-២០០៦ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១០៧៤

១៧-០២-២០០៦ -អនុក្រឹត្យលេខ ១៤ អនក្រ.បក ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ១០៧៦

១៧-០២-២០០៦ -អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ ១០៧៩

IV. ការងារបណ្តាក្រសួង

១. នីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៦-០២-២០០៦ -សេចក្តីណែនាំលេខ ០០៣ សហវ.មមព ស្តីពីសោហ៊ុយលើសេវាសំណង់ ១០៨២

២. នីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៦-០២-២០០៦ -ប្រកាសលេខ ១៩៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ម៉ាអ៊ីស្រ្តីយ៉ា ខេមបូឌា ខូ.អិលធីឌី** បង្កើតរោងចក្រ " ផលិតថ្នាំលាប " ដែលមានឈ្មោះថា " ម៉ាអ៊ីស្រ្តីយ៉ា ខេមបូឌា ខូ.អិលធីឌី " ១០៨៤

១៧-០២-២០០៦ -ប្រកាសលេខ ១៩៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ធៀវ៉ុន យ៉ី អ៊ិនដាសស្រ្ទៀល ដីវេឡុបមេន** បង្កើតរោងចក្រ " ផលិតចំណីសត្វ " ដែលមានឈ្មោះថា " ធៀវ៉ុន យ៉ី អ៊ិនដាសស្រ្ទៀល ដីវេឡុបមេន " ១០៨៦

២២-០២-២០០៦ -ប្រកាសលេខ ២២៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **គ្លូរី វុន ស៊ូ ខមភេនី លីមីធីត** បង្កើតរោងចក្រ " ស្បែកជើង " ដែលមានឈ្មោះថា " គ្លូរី វុន ស៊ូ ខមភេនី លីមីធីត " ១០៨៨

៣. នីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៤-០២-២០០៦ -ប្រកាសលេខ ០៧៨ ប្រក.កសក.ប ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ១០៩០

៤. នីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

១៧-០២-២០០៦ -ប្រកាសលេខ ៣១៨ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " ទួលស្វាយព្រៃ " ទៅជាវិទ្យាល័យ " ទួលស្វាយព្រៃ " ស្ថិតនៅក្នុងសង្កាត់ ទួលស្វាយព្រៃ II ខណ្ឌចំការមន ក្រុងភ្នំពេញ ១០៩៧

១៧-០២-២០០៦ -ប្រកាសលេខ ៣១៩ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ " ទឹកផុំ " ទៅជាអនុវិទ្យាល័យ " អភិវឌ្ឍន៍ " ស្ថិតនៅក្នុងឃុំ អភិវឌ្ឍន៍ ស្រុក ទឹកផុំ ខេត្តកំពង់ឆ្នាំង ១០៩៨

២០-០២-២០០៦ -ប្រកាសលេខ ៣២២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " ព្រៃស្វាយ " ស្ថិតនៅក្នុងឃុំ ព្រៃស្វាយ ស្រុក មោងឫស្សី ខេត្តបាត់ដំបង ១១០០

២០-០២-២០០៦ -ប្រកាសលេខ ៣២៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ " គិរីចុងកោះ " ទៅជា អនុវិទ្យាល័យ " សុខ អាន គិរីចុងកោះ " ស្ថិតនៅក្នុងឃុំ គិរីចុងកោះ ស្រុក គិរីវង់ ខេត្តតាកែវ ១០៩៩

៥-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

០២-១២-២០០៥ -លិខិតលេខ ២៧០៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អាល់ហ្វា ម៉ែត្រលេកស៊ី (ខេមបូឌា)** ១១០២

០២-១២-២០០៥ -លិខិតលេខ ២៧០៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឡា ឡា លែន** ១១០៤

០៦-១២-២០០៥ -លិខិតលេខ ២៧១៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេស៊ា វើលដ៍ អេគ្រី ខលឈើរល ឌីវេឡុបមេន (ខេមបូឌា) លីមីធីត** ១១០៦

០៦-១២-២០០៥ -លិខិតលេខ ២៧១៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **វើលដ៍ ថីម្ភោឌើរ** ១១០៨

០៦-១២-២០០៥ -លិខិតលេខ ២៧២៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **វីអូ គ្រុប ខមតេនី លីមីធីត** ១១១០

០៣-០១-២០០៦ -លិខិតលេខ ០២២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេ ធី ហ្សេត ទ្រេនឌីង** ១១១២

០៣-០១-២០០៦ -លិខិតលេខ ០៤៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **កម្លាំងយក្ស** ១១១៤

២៣-០១-២០០៦ -លិខិតលេខ ២៩៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម្លូ សហ្វៃរ ឌីវេឡុបមេន អិលធីឌី** ១១១៦

២៣-០១-២០០៦ -លិខិតលេខ ២៩៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ត៏.អេ.អិល គ្រុប** ១១១៨

២៤-០១-២០០៦ -លិខិតលេខ ៣០៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឌុលតិន ប្រាឌើ ខូ អិលធីឌី** ១១២០

២៤-០១-២០០៦ -លិខិតលេខ ៣០៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អ៊ី ឆ្លីហ្សឹម (ខេមបូឌា)** ១១២២

ឃ

២៤-០១-២០០៦ -លិខិតលេខ ៣០៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី តី ជី ប្រូតិចសិន អិលធីឌី** ១១២៤

២៤-០១-២០០៦ -លិខិតលេខ ៣១០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អិល ខេ (ជា អិលខេ) អិលធីឌី** ១១២៦

ព្រះរាជក្រឹត្យ

នស/រកត/០២០៦/០៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី ចូវ ឌីនញី (CHAU DINH NHI) ជនជាតិវៀតណាម សញ្ជាតិបារាំង កើតថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៥៤ នៅខេត្ត ចូឡុង ប្រទេសវៀតណាម។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៤.០៦០២.០៧៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០០៦

លេខៈ ៣៧៩ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០២០៦/០៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ហាន់ដា ហារុហ៊ីសា (HANDA HARUHISA) សញ្ជាតិជប៉ុន កើតថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៥១ នៅយ៉ូហ្គូ ព្រីហ្វិចហ្វេ ប្រទេសជប៉ុន។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ល-០២០៦-០៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៦

លេខៈ ៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណរី តាន់

នស/រកត/០២០៦/០៧៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម នឹម សិន ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

ពាល.០២០៦.០៨៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៦

លេខ: ៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស្វាយ សាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ:...០២...ព.រ.ក

សេចក្តីសម្រេចរួម
ស្តីពី
ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន របស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩ /៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី ២នៃព្រឹទ្ធសភាសំរាប់នីតិកាលទី ១
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា
- បានឃើញកំណត់ហេតុសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី ១ នីតិកាលទី ៣ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី ២ នៃរដ្ឋសភាសំរាប់នីតិកាលទី ៣
- បានឃើញព្រះរាជក្រមលេខ ជស/រកម /០៤៩៨ /០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២២១ ចុះថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់អាណត្តិ ៣ ឆ្នាំ លើកទី ៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញសេចក្តីសម្រេចរួមលេខ ០១ ព.រ.ក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- យោងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ : ១៤០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

សម្រេច

មាត្រា ១:

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៤ វាក្យខណ្ឌទី ១ នៃសេចក្តីសម្រេចរួមលេខ ០១ ព.រ.ក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗរបស់ មន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ ត្រូវកែប្រែពីចំនួន៣០០៛ (បីរយរៀល) ទៅចំនួន ៤០០៛ (បួនរយរៀល)ក្នុងមួយសន្ទស្សន៍ ។

មាត្រា ២:

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

មាត្រា ៣:

អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភា និង អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៤:

សេចក្តីសម្រេចនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៦

ប្រធានព្រឹទ្ធសភា	ប្រធានរដ្ឋសភា	ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ជា ស៊ីម	នរោត្តម រណឫទ្ធិ	ប៊ិន ឈិន

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកិច្ចការនារី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣០០/១០ ចុះ ថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី សវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

សម្រេច

មាត្រា១.-

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងកិច្ចការនារីបំពេញបន្ថែមឱ្យ អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកិច្ចការនារី ។

មាត្រា២.-

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តា ស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ការិយាល័យ ចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ។

មាត្រា៣.-

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច :

- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិនិងដៃគូភ្នាក់ងារផ្តល់ជំនួយដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ការងារគ្រប់វិស័យរបស់ក្រសួង
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំពិធីការសម្រាប់ថ្នាក់ដឹកនាំ កិច្ចប្រជុំនានា និងពិធីផ្សេងៗរបស់ក្រសួង ជាមួយភ្ញៀវបរទេស
- សម្រួលលិខិតស្នាមដូចជា លិខិតឆ្លងដែន ទិដ្ឋាការ របស់មន្ត្រីរាជការក្រោមឱវាទក្រសួងដែលត្រូវទៅបំពេញបេសកកម្មក្រៅប្រទេសតាមការចាត់តាំងរបស់ក្រសួង និងជំនាញការបរទេស ដែលបំពេញការងារជាមួយក្រសួង
- ទទួលបន្ទុកកិច្ចការអាស៊ានលើវិស័យកិច្ចការនារី
- រៀបចំគំរោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយអន្តរជាតិដែលពាក់ព័ន្ធនិងវិស័យកិច្ចការនារីតាមគោលការណ៍របស់រាជរដ្ឋាភិបាល
- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធ នឹងកិច្ចការអន្តរជាតិ សម្រាប់ចរចា និងចុះហត្ថលេខាលើកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ
- តាមដាន និងវាយតម្លៃលើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យកិច្ចការនារីដែលបានចែងក្នុង

កំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ជូនថ្នាក់ដឹកនាំ ដើម្បីបង្កើនប្រសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ

-បូកសរុប និងវាយតំលៃរាល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដែលបានចុះពិធីសារ ជាមួយក្រសួងហើយរាយការណ៍ពីលទ្ធផល នៃការងារទាំងនោះដោយសុំមតិកែសម្រួល ឬសុំបញ្ចប់កិច្ចព្រមព្រៀងណាមួយដែលអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍កំណត់

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធាន មួយចំនួនជាជំនួយការ ។

របនាសម្ព័ន្ធ នៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។

មាត្រា ៤.-

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យ នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី

អ៊ឹង កន្ថាផាវី

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៣...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ជស / រកម / ០៣០០ / ១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតំឡើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ស ម្រេ ច

មាត្រា ១ : ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

មាត្រា ២ : នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ច តាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រីសូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សូរ ឃុន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមែងក្នុងមាត្រា ៤*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលអនុក្រឹត្យលេខ ៣៩ អនក្រ.បកចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៩អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា
- យោងតាមភាពចាំបាច់នៃការងារ

សម្រេច

មាត្រា១: ត្រូវបានកែសម្រួលមាត្រា២ និងមាត្រា៣នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បកចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៤ ស្តីពីការ បង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជាដូចតទៅ :

មាត្រា២ថ្មី: អាជ្ញាធរជាតិទេសចរណ៍កម្ពុជាមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **វេង សិរីវុឌ្ឍ**	ទេសរដ្ឋមន្ត្រី	ប្រធាន
២- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ប៉ាណារ៉ា សិរីវុឌ្ឍ**	រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	អនុប្រធាន
៣- ឯកឧត្តម **លាយ ប្រាហាស់**	រដ្ឋមន្ត្រីក្រសួងទេសចរណ៍	អនុប្រធាន
៤- ឯកឧត្តម **ថោង ខុន**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន

៥- ឯកឧត្តម សេង លឹមនៅ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធានប្រចាំការ

៦- ឯកឧត្តម ឌួច ស៊ាងតារ៉ាណា សមាជិក កសសស (OBSES) អនុប្រធាន

៧- ឯកឧត្តម ព្រាំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៨- ឯកឧត្តម ឡុង វិសាលោ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩- ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០- ឯកឧត្តម ទ្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១១- ឯកឧត្តម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១២- ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ សមាជិក

១៣- ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៤- ឯកឧត្តម ថាវ់ ជែន រដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក

១៥- ឯកឧត្តម ពេជ្រ សោភ័ណ រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៦- ឯកឧត្តម ម៉ុន ណារិទ្ធ អគ្គនាយក អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា សមាជិក

១៧- ឯកឧត្តម សូ ម៉ារ៉ា អគ្គលេខាធិការ "អជទក" និងជាអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១៨- ឯកឧត្តម សយ សុខាន់ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

១៩- លោក យុន ឈុន្នី ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

មាត្រា៣ថ្មី: អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ជួយរាជរដ្ឋាភិបាល ក្នុងការរៀបចំកសាងគោលនយោបាយ យុទ្ធសាស្ត្រជាតិ ផែនការអភិវឌ្ឍន៍ ការត្រួតពិនិត្យ និងសម្របសម្រួលការងារអនុវត្ត លើការអភិវឌ្ឍន៍វិស័យ ឧស្សាហកម្ម ទេសចរណ៍ជាតិ
- ត្រៀមការងារជូនរាជរដ្ឋាភិបាល ដើម្បីសម្រេចលើគម្រោងអភិវឌ្ឍន៍ ឬវិនិយោគនានា នៃ វិស័យឧស្សាហកម្មទេសចរណ៍
- ណែនាំក្រសួងទេសចរណ៍ ក្នុងការតាមដាន បញ្ជាក់ និងឆ្លុះបញ្ចាំងលទ្ធផល នៃការអនុវត្ត កម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ ព្រមទាំងផែនការសកម្មភាពទាំងឡាយដែលទាក់ទងដល់ កិច្ចអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍
- កំណត់កិតអាទិភាព សំរាប់កិច្ចអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍
- ទទួលបន្ទុករៀបចំ និងលើកគម្រោងការងារ ផ្សព្វផ្សាយ ទីផ្សារទេសចរណ៍ រួមទាំង ព្រឹត្តិការណ៍ ទេសចរណ៍
- ទទួលបន្ទុករៀបចំ និងលើកគម្រោងការងារសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរណ៍

- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងសមាគមទាំងឡាយ ដែលប្រកបអាជីវកម្មវិស័យឧស្សាហកម្មទេសចរណ៍ លើការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព ដែលជាប់ទាក់ទងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មទេសចរណ៍ ដោយឈរលើមូលដ្ឋាននៃផែនការ អភិវឌ្ឍន៍ជាតិ
- សហការជាមួយអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ក្នុងការលើកគម្រោងអភិវឌ្ឍវិស័យ ទេសចរណ៍ នៅតំបន់សៀមរាប អង្គរ និង តំបន់ពាក់ព័ន្ធ ផ្សេងទៀត
- ទទួលខុសត្រូវក្នុងការអភិរក្ស និងអភិវឌ្ឍតំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គនៃខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់អោយបានទៀងទាត់ ជូនប្រមុខ រាជរដ្ឋាភិបាល ។

មាត្រាពីរ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រាបី : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា២ថ្មី ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៥....អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោត ទន្លេមេគង្គ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៩អនក្រ.បក ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់

សម្រេច

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម នូច ម៉ិនសារ៉ាណា	សមាជិក កសសស (OBSES)	ជាប្រធាន
២- ឯកឧត្តម ម៉ោន ខុន	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
៣- ឯកឧត្តម ឆើ ធ្វី	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ	អនុប្រធាន
៤- ឯកឧត្តម ខាំ ឆឿន	អភិបាលខេត្តក្រចេះ	អនុប្រធាន

៥-ឯកឧត្តម **ឡុង ផល**	អភិបាលរងទី ១ ខេត្តស្ទឹងត្រែង	អនុប្រធាន
៦-ឯកឧត្តម **ដួង លឿង**	មេធាវីរាជរដ្ឋាភិបាល	សមាជិក
៧-ឯកឧត្តម **ណៅ ធួក**	សមាជិក កសសស និងជាប្រធាននាយកដ្ឋានជលផល	សមាជិក
៨-ឯកឧត្តម **ចាន់ រ៉ាស៊ី**	អគ្គលេខាធិការរង កសសស	សមាជិកអចិន្ត្រៃយ៍
៩-លោក **សូ នាក់**	ស្នងការនគរបាលខេត្តក្រចេះ	សមាជិក
១០-លោក **ឆា គៀត**	មេបញ្ជាការកងរាជអាវុធហត្ថខេតខេត្តក្រចេះ	សមាជិក
១១-លោក **មុត ម៉ៅ**	ស្នងការនគរបាលខេត្តស្ទឹងត្រែង	សមាជិក
១២-លោក **សឿន ប៊ុនរិទ្ធ**	មេបញ្ជាការកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង	សមាជិក
១៣-លោក **កែវ រតនៈ**	នាយកខុទ្ទកាល័យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក

មាត្រា ២.-

គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

- ធ្វើការអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីតម្លៃនៃសត្វផ្សោត ដែលជិតផុតពូជ និងតម្លៃបេតិកភ័ណ្ឌធម្មជាតិរបស់សត្វផ្សោតនៅតំបន់ទេសចរណ៍សត្វផ្សោត ឱ្យមានការអភិរក្ស និងអភិវឌ្ឍ ប្រកបដោយនិរន្តរភាព
- ចាត់តាំងមន្ត្រីភ្នាក់ងារប្រចាំការនៅតំបន់មានសត្វផ្សោត ទាំងលើគោក និងក្នុងទន្លេ ដោយសហការជាមួយសហគមន៍ និងអាជ្ញាធរដែនដីមូលដ្ឋាន
- ស្វែងរកជំនួយ សម្ភារៈ និងថវិកា ក្នុងនិងក្រៅប្រទេស ដើម្បីបំរើការងារអភិរក្ស និងជួយបង្កលក្ខណៈឱ្យប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានមានមុខរបរផ្សេងជំនួសការនេសាទត្រី ក្នុងតំបន់មានសត្វផ្សោត
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការកំណត់ទំហំនៃតំបន់អភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោត
- រៀបចំសេចក្តីព្រាងផែនការមេ និងផែនការសកម្មភាព ក្នុងការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ
- សហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបំរើគោលដៅអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតប្រកបដោយនិរន្តរភាព
- ធ្វើរបាយការណ៍ជាប្រចាំតាមកាលកំណត់អំពីលទ្ធផលការងារ ជូនអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៣.-

- គណៈកម្មការនេះមានទីតាំងទីស្នាក់ការកណ្តាលនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានទីស្នាក់ការជាសាខានៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ព្រមទាំងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការ-គណៈរដ្ឋមន្ត្រី
- សមាជិកនៃគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

- ប្រធានគណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមប្រជុំតាមការចាំបាច់។

មាត្រា ៤.-

គណៈកម្មការនេះមានថវិកាសម្រាប់ចំណាយក្នុងសកម្មភាពការងាររបស់ខ្លួន នៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងមានប្រភពចំណូលមកពីជំនួយអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងចំណូលផ្សេងៗទៀត។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣ សហវ.ណន

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៦

សេចក្តីណែនាំ
ស្តីពី
សោហ៊ុយលើសេវាសំណង់

ដោយអនុក្រឹត្យលេខ ៨៦ អនក្រ. បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតិសាងសង់ពុំមានកំណត់តំលៃនៃសេវាសំណង់នៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញប្រកាសអន្តរក្រសួងស្តីពីសោហ៊ុយលើសេវាសំណង់ដើម្បីប្រមូលចំណូលមិនមែនសារពើពន្ធស្របតាមច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

ដើម្បីកុំឱ្យការអនុវត្តមានការខុសឆ្គង ដោយបកស្រាយខុសពីខ្លឹមសារនៃអង្គប្រជុំអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំនូវលើប្រការមួយចំនួន នៃប្រកាសអន្តរក្រសួងលេខ ០៣៣ សហវ.ប្រក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៦ នេះ ដូចខាងក្រោម :

ទី១ -ពេលចុះបេសកកម្មមន្ត្រីជំនាញត្រូវគោរពក្រមសីលធម៌ វិជ្ជាជីវៈ និងច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលពោល គឺ មិនត្រូវទាមទារពីម្ចាស់សំណង់នូវសោហ៊ុយហូបចុក ស្នាក់នៅ ហួសពីកំរិតប្រហាក់ប្រហែល ដែលមានចែងក្នុងអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របប បេសកកម្មក្នុង និងក្រៅប្រទេស ។

ទី២ -ពេលបានការជួយឧបត្ថម្ភ នូវសោហ៊ុយបេសកកម្មក្នុងការហូបចុក ស្នាក់នៅ ពីម្ចាស់សំណង់រួចហើយមិនត្រូវទាមទាររបបឧបត្ថម្ភ បន្ថែមពីរដ្ឋទៀតឡើយ ។

ទី៣ -រាល់ទំរង់បែបបទ និង សំណុំឯកសារ ពាក់ពន្ធ័នឹងការសុំ និង ការផ្តល់អាជ្ញាបណ្ណ័ សាងសង់ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា១៤របស់អនុក្រឹត្យលេខ៨៦ អនក្រ.ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលបានកំណត់ត្រឹម៤៥ ថ្ងៃធ្វើការដោយគិតពីថ្ងៃបានបំពេញសព្វគ្រប់នូវរាល់លិខិតស្នាមដែលត្រូវភ្ជាប់ជាមួយពាក្យសុំលិខិតអនុញ្ញាតសាងសង់ដើម្បីជៀសវាងការអូសបន្លាយពេលវេលាដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ម្ចាស់សំណង់ ។

ទី៤ -ប្រកាសនេះបានកំណត់ អប្បហារជាផ្លូវការជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់រួចហើយ ដូច្នេះមិនត្រូវទាមទារបន្ថែមកំរៃ ក្រៅពីសោហ៊ុយសេវាសំណង់ដែលមាននៅក្នុងបង្កាន់ដៃឡើយ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-724 664 Fax : 855-23-427 798

ទី៥ -ដើម្បីឱ្យមានតម្លាភាព សោហ៊ុយសេវាសំណង់នេះ ត្រូវបានផ្សព្វផ្សាយ ជាសាធារណៈ ឱ្យបានទូលំទូលាយ ព្រមទាំងមានបិទផ្សព្វផ្សាយ នៅគ្រប់អង្គភាព ដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ។

ទី៦ -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងចាត់បញ្ជូនមន្ត្រីជំនាញរបស់នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ចុះតាមដានត្រួតពិនិត្យ ជាប្រចាំដើម្បីធានាការអនុវត្តប្រកាសនេះប្រកបដោយសមធម៌ ត្រឹមត្រូវតាមច្បាប់ និងធានាបាននូវតុល្យភាពរវាងផលប្រយោជន៍រដ្ឋ និង ផលប្រយោជន៍ប្រជាពលរដ្ឋជាម្ចាស់សំណង់។

ទី៧ -ក្នុងករណីពិនិត្យឃើញថា ការអនុវត្តប្រកាសអន្តរក្រសួង ស្តីពីសោហ៊ុយលើសេវាសំណង់មានបញ្ហារាំងស្ទះឬបង្កការលំបាកដល់ម្ចាស់សំណង់ហួសហេតុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចូលរួមរៀបចំធ្វើការកែតំរូវប្រកាសនេះជាថ្មីឱ្យបានសមហេតុសមផលវិញ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កន្លែងទទួល:

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
  " ដើម្បីមុខការ និង ផ្សព្វផ្សាយដល់អង្គភាពក្រោមឱវាទ "
- អភិបាល ខេត្ត ក្រុង
  " ដើម្បីជ្រាបជាពតិមាន "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៩៦ ឧរថ.ករ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២១៧៤/៩៧ គ.វ.ក ចុះថ្ងៃទី ២២.០៧.១៩៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ម៉ាអ៊ីស្ទ្រីយ៉ា ខេមបូឌា ខូ.អិលធីឌី ចុះថ្ងៃទី ២៤.០១.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាអ៊ីស្ទ្រីយ៉ា ខេមបូឌា ខូ.អិលធីឌី (MAESTRIA CAMBODIA CO., LTD.) តំណាងដោយលោក ប៊ិន ឃុន សញ្ជាតិខ្មែរ អាយុ៤០ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណ 010044641 ចុះថ្ងៃទី២៧.០៧.២០០១ បង្កើតរោងចក្រ "ផលិតថ្នាំលាប" ដែលមានឈ្មោះថា "ម៉ាអ៊ីស្ទ្រីយ៉ា ខេមបូឌា ខូ.អិលធីឌី (MAESTRIA CAMBODIA Co., LTD.)"មានទីតាំងស្ថិតនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្ដម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយក្រុមហ៊ុនត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់មកក្រសួង ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតថ្នាំលាប" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ម៉ាអ៊ីស្រ្ទីយ៉ា ខេមបូឌា ខូ.អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
ស្តីការគណៈរដ្ឋមន្ត្រី
ាជកិច្ច
្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
្រសួងបរិស្ថាន
្រសួងពាណិជ្ជកម្ម
ាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
ួចប្រការ ៩ "ដើម្បីអនុវត្ត"
ាកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ១៩៧ ឧសថ. កឧ. ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០០៤ អគវ២ ចុះថ្ងៃទី ១៦.០១.២០០៦ របស់អនុគណៈកម្មាធិការវិនិយោគខេត្តកណ្តាល
- បានឃើញលិខិតលេខ ០១ រ.ឧរថ ចុះថ្ងៃទី ២៥.០១.២០០៦ របស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ធៀន យី អ៊ិនដាសស្ទ្រៀល ដីវេឡុបមេន ចុះថ្ងៃទី ២២.១២.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ធៀន យី អ៊ិនដាសស្ទ្រៀល ដីវេឡុបមេន (TIAN YEE INDUSTRIAL DEVELOPMENT CO., LTD.) តំណាងដោយ លោក WU YOULIANG សញ្ជាតិចិន អាយុ៦០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G13832669 ចុះថ្ងៃទី១៥.០៣.២០០៥ បង្កើតរោងចក្រ“ផលិតចំណីសត្វ ”ដែលមានឈ្មោះថា “ ធៀន យី អ៊ិនដាសស្ទ្រៀល ដីវេឡុបមេន (TIAN YEE INDUSTRIAL DEVELOPMENT)”មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ២ ភូមិក្រាំងស្វាយ ឃុំព្រែកកំពឹស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ៸ ហ

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតម្កល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតចំណីសត្វ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត កណ្តាល និង ប្រធានក្រុមហ៊ុន ធៀន យី អ៊ិនដាសស្ទ្រៀល ឌីវេឡុបមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-អនុគណៈកម្មាធិការវិនិយោគខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ២២៣ ឧស្ស. ករ. ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៩៣/០៦ ត.រ.ក ចុះថ្ងៃទី០៦.០២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន គ្លរី វុន ស៊ូ ខមភេនី លីមីធីត ចុះថ្ងៃទី១២.០១.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន គ្លរី វុន ស៊ូ ខមភេនី លីមីធីត (GLORY WON SHOE COMPANY LIMITED) តំណាងដោយ លោក HSUEH, HSUEH-YUNG សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 212335084 ចុះថ្ងៃទី២១.០៣.២០០៥ បង្កើតរោងចក្រ "ស្បែកជើង" ដែលមានឈ្មោះថា " គ្លរី វុន ស៊ូ ខមភេនី លីមីធីត (GLORY WON SHOE COMPANY LIMITED) " មានទីតាំងស្ថិតនៅ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ"ផលិតស្បែកជើង"ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្ដូរមុខផលិតផល ផ្លាស់ប្ដូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុន ត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន គ្វីរ វុន ស៊ូ ខមភេនី លីមីធីត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ០៧៥ ប្រក.កសក.ប

ប្រកាស

ស្តីពី

ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញប្រកាសលេខ ៥២៦ ប្រក.កសក.ប ចុះថ្ងៃទី ១៣ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការផ្ទេរការិយាល័យ និងមន្ត្រីដឹកនាំ ឱ្យទៅនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- យោងតាមតម្រូវការចាំបាច់ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

ប្រការ១ : នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ជានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចដូចតទៅ ÷

- សម្របសម្រួល និង ទំនាក់ទំនងការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ជាមួយអន្តរជាតិ ដែលពាក់ពន្ធ័នឹងវិស័យកសិកម្ម តាមគោលការណ៍របស់រាជរដ្ឋាភិបាល
- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ពន្ធ័នឹងកិច្ចការអន្តរជាតិ ជូនថ្នាក់ដឹកនាំក្រសួង សម្រាប់ចរចារ និង ចុះហត្ថលេខាលើកំណត់ហេតុ អនុស្សារណៈ ពិធីសារ និង កិច្ចព្រមព្រៀងផ្សេងៗ
- គ្រប់គ្រង និង សម្របសម្រួលរាល់សកម្មភាពគ្រប់អង្គភាព ដែលដំណើរការក្រោមឥណទាន របស់ជំនួយ ទ្វេភាគី ពហុភាគី ជាមួយរាជរដ្ឋាភិបាល ឬជាមួយក្រសួង ស្ថាប័ននានា
- តាមដាន និង វាយតម្លៃ លើការអនុវត្តរាល់ខ្លឹមសារពាក់ពន្ធ័ជាមួយវិស័យកសិកម្ម ដែលបានចែងក្នុង កំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និង កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា
- ចងក្រង និង គ្រប់គ្រងទិន្នន័យ ឯកសារដែលទាក់ទងនឹងកិច្ចការអន្តរជាតិ លើវិស័យកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួន ជាជំនួយការ ។

ប្រការ២ : នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានការិយាល័យចំណុះ ដូចខាងក្រោម ÷

១- ការិយាល័យ រដ្ឋបាល និង បុគ្គលិក

២- ការិយាល័យ ការងារអង្គការអន្តរជាតិ

៣- ការិយាល័យ សហប្រតិបត្តិការទ្វេភាគី និង ពហុភាគី

៤- ការិយាល័យ អាស៊ានកសិកម្ម

៥- ការិយាល័យ កសិ-ពាណិជ្ជកម្មពិភពលោក

ប្រការ៣ : ការិយាល័យចំណុះនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ ។

ប្រធានការិយាល័យ ត្រូវទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋាន នូវរាល់ការងារក្នុង ការិយាល័យ ។ អនុប្រធានការិយាល័យជាអ្នក ជំនួយការឱ្យប្រធានការិយាល័យ និងទទួលខុសត្រូវ ចំពោះមុខប្រធានការិយាល័យ លើរាល់សកម្មភាពការងារ ហើយត្រូវរួមគ្នាជាមួយប្រធានការិយាល័យ ទទួលខុសត្រូវនូវរាល់ការងារក្នុងការិយាល័យ ។

ប្រការ៤ : តួនាទី ភារកិច្ចរបស់ការិយាល័យនីមួយៗ មានដូចតទៅ ÷

៤-១ ការិយាល័យរដ្ឋបាល និង បុគ្គលិក មានភារកិច្ច :

- គ្រប់គ្រង ចរាចរឯកសាររដ្ឋបាលផ្សេងៗ និងតម្កល់ទុកឯកសារ
- គ្រប់គ្រងស្ថិតិ និង ក្របខណ្ឌមន្ត្រីរាជការ
- រៀបចំគំរោងអភិវឌ្ឍន៍ធនធានមនុស្ស និង ចាត់ចែងមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ
- រៀបចំកម្មវិធី និងកាលវិភាគការងារជូនថ្នាក់ដឹកនាំនាយកដ្ឋាន និង ការងារពិធីការ
- កសាងផែនការការងាររយៈពេលខ្លី មធ្យម និង វែង របស់នាយកដ្ឋាន
- រៀបចំគម្រោងថវិកា សម្រាប់ដំណើរការការងារប្រចាំឆ្នាំ របស់នាយកដ្ឋាន
- លើកសំណើតែងតាំង បន្ថយឋានៈ សម្រួលភារកិច្ច ឬកែសម្រួលរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែង
- គ្រប់គ្រង បែងចែកសម្ភារៈការិយាល័យ និង គ្រប់គ្រងថែរក្សាចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់នាយកដ្ឋាន
- រៀបចំការងារបៀវត្ស តម្លើងកាំបៀវត្ស ចូលនិវត្តន៍ របបធានារ៉ាប់រងសង្គម និង ការងារផ្តល់គ្រឿងឥស្សិរយយសជូនមន្ត្រីរាជការ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ និងលើកទិសដៅបន្ត
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

៤-២ ការិយាល័យការងារអង្គការអន្តរជាតិ មានភារកិច្ច :

- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត លើការងារអង្គការអន្តរជាតិដែលពាក់ព័ន្ធដល់វិស័យកសិកម្ម
- សម្របសម្រួល រៀបចំរាល់សិក្ខាសាលា ការងារពិធីការនានា ដែលរៀបចំសហការឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងបណ្តាអង្គការអន្តរជាតិ
- ពិនិត្យ សម្របសម្រួលលើរាល់ឯកសារ កំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ របស់អង្គការអន្តរជាតិ
- ចងក្រង និង គ្រប់គ្រងទិន្នន័យ ឯកសារដែលទាក់ទងនឹងកិច្ចការរបស់អង្គការអន្តរជាតិ លើវិស័យកសិកម្ម
- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការ កំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និង កិច្ចព្រមព្រៀងផ្សេងៗ ជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចរចា និង ចុះហត្ថលេខា
- សម្របសម្រួលរាល់សកម្មភាពគ្រប់អង្គភាព ដែលដំណើរការក្រោមឥណទាន របស់ជំនួយអង្គការអន្តរជាតិ ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា
- តាមដាន និង ផ្តល់យោបល់លើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធ ជាមួយវិស័យកសិកម្ម ដែលបាន

ចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា

- តាមដាន និង ផ្តល់យោបល់លើការអនុវត្តគម្រោងសហប្រតិបត្តិការ ជាមួយអង្គការអន្តរជាតិ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

៤-៣ **ការិយាល័យសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី មានភារកិច្ច :**

- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើការងារសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ជាមួយបណ្តាប្រទេសជាដៃគូ
- ទទួលបន្ទុកការងារសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាដៃគូ ដែលពាក់ព័ន្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- សម្របសម្រួល និងសហការរៀបចំរាល់សិក្ខាសាលា និង ការងារពិធីការនានា ដែលរៀបចំសហការឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងបណ្តាប្រទេសជាដៃគូ
- សម្របសម្រួល ផ្តល់យោបល់ និងអនុវត្តការងារបញ្ជូនមន្ត្រីរាជការទៅចូលរួមប្រជុំ សិក្ខាសាលា ក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ជាមួយបណ្តាប្រទេសជាដៃគូ
- សម្របសម្រួល រាល់សំណើគម្រោងសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាមួយបណ្តាប្រទេសជាដៃគូ
- សម្របសម្រួលបែបបទ ដើម្បីសុំលិខិតឆ្លងដែន ទិដ្ឋាការផ្លូវការ របស់មន្ត្រីរាជការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ទិដ្ឋាការស្នាក់នៅរបស់បុគ្គលិកអង្គការអន្តរជាតិ ដែលកំពុងសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ពិនិត្យ និង រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការសហប្រតិបត្តិការនានា របស់បណ្តាប្រទេសជាដៃគូ ជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចរចារ និងចុះហត្ថលេខាលើកំណត់ហេតុ អនុស្សារណៈ ពិធីសារ និង កិច្ចព្រមព្រៀងផ្សេងៗ
- សម្របសម្រួលរាល់សកម្មភាពគ្រប់អង្គភាព ដែលដំណើរការក្រោមឥណទានរបស់ជំនួយទ្វេភាគី និង ពហុភាគី ជាមួយរាជរដ្ឋាភិបាល ឬជាមួយក្រសួង ស្ថាប័ននានា
- តាមដាន និងផ្តល់យោបល់លើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធ ជាមួយវិស័យកសិកម្ម ដែលបានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា
- តាមដាន និង ផ្តល់យោបល់លើការអនុវត្តគម្រោងសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ជាមួយបណ្តាប្រទេសជាដៃគូ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

៤-៤ ការិយាល័យអាស៊ានកសិកម្ម មានភារកិច្ច :

- សម្របសម្រួល និងទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលេខាធិការដ្ឋានអាស៊ាន រាល់ការងារសហប្រតិបត្តិការលើវិស័យកសិកម្ម ជាមួយបណ្ដាប្រទេសជាសមាជិកអាស៊ាន និងដៃគូអាស៊ាន
- សម្របសម្រួលជូនមន្ត្រីកសិកម្ម ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា លើវិស័យកសិកម្ម ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន
- សម្របសម្រួល រៀបចំធ្វើជាម្ចាស់ផ្ទះនូវកិច្ចប្រជុំអាស៊ាននានា ដែលពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម
- តាមដាន វាយតម្លៃការអនុវត្តគម្រោងសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន និង ដៃគូអាស៊ាន
- សហការជាមួយបណ្ដានាយកដ្ឋានជំនាញ ក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍វិស័យកសិកម្មក្នុងក្របខណ្ឌតំបន់អាស៊ាន ដើម្បីសុំការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីលេខាធិការដ្ឋានអាស៊ាននិងប្រទេសជាដៃគូអាស៊ាន
- សិក្សាស្រាវជ្រាវ ធ្វើឱ្យមានភាពស្របគ្នា ក្នុងក្របខណ្ឌអាស៊ាន នូវច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងវិស័យកសិកម្ម
- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការអាស៊ាន លើវិស័យកសិកម្ម ជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចូលរួមប្រជុំចរចារ និងចុះហត្ថលេខាលើកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ ក្នុងក្របខណ្ឌអាស៊ាន
- តាមដាន និងផ្ដល់យោបល់លើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធ ជាមួយវិស័យកសិកម្ម ដែលបានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាក្នុងក្របខណ្ឌអាស៊ាន
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

៤-៥ ការិយាល័យកសិ-ពាណិជ្ជកម្មពិភពលោក មានភារកិច្ច :

- តាមដាន និង ទំនាក់ទំនងកិច្ចសហប្រតិបត្តិការផ្នែក កសិ-ពាណិជ្ជកម្មពិភពលោក ជាមួយអគ្គលេខាធិការដ្ឋានពាណិជ្ជកម្មពិភពលោក អង្គការអន្តរជាតិនានា ក្រសួង និង ស្ថាប័នពាក់ព័ន្ធ
- ពិនិត្យ សិក្សាលើផែនការយុទ្ធសាស្ត្រ និងវិធានការទប់ទល់នឹងការធ្វើពាណិជ្ជកម្មមិនសមស្របតាមបទបញ្ញត្តិរបស់អង្គការពាណិជ្ជកម្មពិភពលោក របស់ដៃគូពាណិជ្ជកម្ម
- តាមដាន ប្រមូលព័ត៌មាន វាយតម្លៃស្ថានភាព តុល្យភាព នៃការធ្វើកសិ-ពាណិជ្ជកម្មពិភពលោក
- សម្របសម្រួល លើការដោះស្រាយវិវាទ ក្នុងការធ្វើកសិ-ពាណិជ្ជកម្មពិភពលោក ជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការពាណិជ្ជកម្មពិភពលោក

- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការកំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងផ្សេងៗ ជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចរចារ និងចុះហត្ថលេខា
- តាមដាន និងផ្តល់យោបល់លើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធ ជាមួយវិស័យកសិកម្ម ដែលបានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និង កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាក្នុងក្របខណ្ឌកសិ-ពាណិជ្ជកម្មពិភពលោក
- តាមដាន និងផ្តល់យោបល់លើការអនុវត្តការងារសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាដៃគូ និងបណ្តាអង្គការអន្តរជាតិនានាក្នុងក្របខណ្ឌកសិ-ពាណិជ្ជកម្មពិភពលោក
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

ប្រការ៥ : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។ ដោយឡែកប្រកាសលេខ ៥២៦ប្រក.កសក.បុ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការផ្ទេរការិយាល័យនិងមន្ត្រីដឹកនាំឱ្យទៅនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិត្រង់ប្រការ ២ និង ប្រការ ៣ ត្រូវរក្សាទុកជាធរមានដដែល ។

